# ត្រូវមាន ID របស់អ្នកជាស្រេចបាច់ ដើម្បីបោះឆ្នោត

## ជំរើសបីយ៉ាង ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក

### ជំរើសទី 1



**បង្ហាញ ID មួយ នៃណាមួយទាំងនេះ**

- លិខិតបើកបររបស់អ្នក
- ប័ណ្ណអ្វីផ្សេងទៀត ដែលបានចេញឲ្យដោយរដ្ឋាភិបាលកាណាដា (សហព័ន្ធ, ខែត្រ/អាណាខែត្រ ឬតំបន់) ដែលមានរូបថត ឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក

### ជំរើសទី 2



\+



**បង្ហាញ ID ពីរមុខ**

ទាំងពីរមុខត្រូវតែមានឈ្មោះរបស់អ្នក ហើយយ៉ាងហោចណាស់ មួយត្រូវតែមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក

**ឧទាហរណ៍៖**

- ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងរបាយការណ៍ធនាគារ
- វិក្កយប័ត្រទឹកភ្លើង និងប័ណ្ណ ID និស្សិត

**តើពុំមានវត្ថុទាំងនេះឬ? គ្មានបញ្ហាទ្បើយ!**

មើលប**ញ្ជីនៃ ID អាចទទួលយកបាន សំរាប់ជំរើសទី 2** ខាងក្រោម

| D'un gouvernement ou d'un organisme gouvernemental | មកពីរដ្ឋាភិបាលឬភ្នាក់ងាររដ្ឋាភិបាល |
|---|---|
| • carte de membre d'une bande | • ប័ណ្ណសមាជិកភាពកុលសម្ព័ន្ធ |
| • certificat de naissance | • សំបុត្រកំណើត |
| • carte ou certificat de citoyenneté canadienne | • ប័ណ្ណសញ្ជាតិកាណាដា ឬសញ្ញាប័ត្រ |
| • carte d'identité des Forces canadiennes | • អត្តសញ្ញាណប័ណ្ណកងទ័ពកាណាដា |
| • passeport canadien | • លិខិតឆ្លងដែនកាណាដា |
| • carte délivrée par une autorité locale inuite | • ប័ណ្ណបានចេញឲ្យដោយអាជ្ញាធរអ៊ីនូតមូលដ្ឋាន |
| • permis d'arme à feu | • សំបុត្រអនុញ្ញាតកាន់កាប់អាវុធ |
| • chèque ou talon de chèque du gouvernement | • សែករដ្ឋាភិបាល ឬបង្កាន់ដៃសែក |
| • relevé de prestations du gouvernement | • របាយការណ៍នៃអត្ថប្រយោជន៍រដ្ឋាភិបាល |
| • carte d'assurance-maladie | • ប័ណ្ណសុខភាព |



Elections Canada

| | |
|---|---|
| • avis de cotisation d'impôt sur le revenu | • ការប្រមាណពន្ធប្រាក់ចំណូល |
| • carte de statut d'Indien ou confirmation temporaire de l'inscription | • ប័ណ្ណស្ថានភាពឥណ្ឌាន ឬការបញ្ជាក់បណ្តោះអាសន្ន នៃការចុះឈ្មោះ |
| • carte de bibliothèque | • ប័ណ្ណបណ្ណាល័យ |
| • permis ou carte de pêche, de piégeage ou de chasse | • លិខិតអនុញ្ញាត ឬប័ណ្ណ បានចេញឲ្យ សំរាប់នេសាទត្រី ការដាក់អន្ទាក់ ឬប្រមាញ់ |
| • carte d'identité d'une régie des alcools | • អត្តសញ្ញាណប័ណ្ណទិញគ្រឿងស្រវឹង |
| • carte de Métis | • ប័ណ្ណ Métis |
| • carte de la Sécurité de la vieillesse | • ប័ណ្ណសន្តិសុខជន្នាយុ |
| • carte de libéré conditionnel | • ប័ណ្ណមនុស្សជាប់លក្ខខ័ណ្ឌដោះលែង |
| • avis de cotisation ou d'évaluation de l'impôt foncier | • ការប្រមាណពន្ធទ្រព្យ ឬការវាយតម្លៃ |
| • carte de transport en commun | • ប័ណ្ណយានជំនិះសាធារណៈ |
| • carte d'assurance sociale | • ប័ណ្ណលេខធានារ៉ាប់រងសង្គម |
| • document de propriété d'un véhicule | • ម្ចាស់រថយន្ត |
| • carte d'identité de santé d'Anciens Combattants | • អត្តសញ្ញាណប័ណ្ណសុខាភិបាល កិច្ចការអតីតយុទ្ធជន |
| **D'Élections Canada** | **មកពីការបោះឆ្នោតកាណាដា** |
| • formulaire de révision ciblée remis aux résidents d'établissements de soins de longue durée | • ការកែទំរង់បានប៉ង សំរាប់អ្នកមូលដ្ឋាននៃស្ថាប័នថែទាំយូរអង្វែង |
| • carte d'information de l'électeur | • ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត |
| **D'un établissement d'enseignement** | **មកពីវិជ្ជាស្ថានការអប់រំ** |
| • correspondance provenant d'une école, d'un collège ou d'une université | • លិខិតឆ្លើយឆ្លង បានចេញឲ្យដោយសាលារៀន មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ |
| • carte d'identité d'étudiant | • អត្តសញ្ញាណប័ណ្ណនិស្សិត |
| **D'un établissement ou d'un organisme de soins de santé** | **មកពីមន្ទីរសុខាភិបាល ឬអង្គការ** |
| • carte de donneur de sang | • ប័ណ្ណអ្នកឲ្យឈាម |
| • carte de l'INCA | • ប័ណ្ណ CNIB |
| • carte d'hôpital | • ប័ណ្ណមន្ទីរពេទ្យ |

| | |
|---|---|
| • étiquette sur un contenant de médicaments sous ordonnance | • ស្លាកនៅលើដបឱសថវេជ្ជបញ្ជា |
| • bracelet d’identité délivré par un hôpital ou un établissement de soins de longue durée | • ខ្សែដៃអត្តសញ្ញាណ បានចេញឲ្យដោយមន្ទីរពេទ្យ ឬស្ថាប័នថែទាំយូរអង្វែង |
| • carte d’une clinique médicale | • ប័ណ្ណវេជ្ជមន្ទីរសុខភាព |
| **D’une institution financière** | **មកពីស្ថាប័នហិរញ្ញវត្ថុ** |
| • état de compte bancaire | • របាយការណ៍ធនាគារ |
| • carte de crédit | • ប័ណ្ណឥណទាន |
| • relevé de carte de crédit | • របាយការណ៍ប័ណ្ណឥណទាន |
| • état de compte d’une caisse populaire | • របាយការណ៍ឥណទានសហភាព |
| • carte de débit | • ប័ណ្ណដេប៊ិត |
| • certificat, police ou relevé d’assurance | • សំបុត្រធានារ៉ាប់រង ច្បាប់សន្យា ឬរបាយការណ៍ |
| • convention hypothécaire ou état de compte de prêt hypothécaire | • កិច្ចសន្យា ឬរបាយការណ៍ប្រាក់បុលទិញផ្ទះ |
| • état des prestations d’un régime de retraite | • របាយការណ៍គំរោងប្រាក់និវត្តន៍ |
| • chèque personnel | • សែកផ្ទាល់ខ្លួន |
| **D’un organisme privé** | **មកពីអង្គការឯកជន** |
| • carte d’employé | • ប័ណ្ណនិយោជិត |
| • bail ou sous-bail d’habitation | • កិច្ចសន្យាជួលលំនៅដ្ឋាន ឬកិច្ចសន្យាជួលបន្ត |
| • facture d’un service public (p. ex. électricité, eau, services de télécommunication, comme le téléphone, la télévision par câble ou la télévision par satellite) | • វិក្កយប័ត្រទឹកភ្លើង (ដូចជា៖ អគ្គិសនី; ទឹក; សេវាគមនាគមន៍ រួមទាំងទូរស័ព្ទ, ខ្សែកាប ឬផ្កាយរណប) |
| **Lettres de confirmation** | **សំបុត្រនៃការបញ្ជាក់** |
| • lettre d’un curateur public ou d’un tuteur public | • សំបុត្រមកពីអភិរក្សសាធាណៈ, អាណាព្យាបាលសាធារណៈ ឬអ្នកទទួលបន្ទុកសាធារណៈ |
| • lettre de confirmation de résidence délivrée par l’autorité responsable d’une bande ou d’une réserve des Premières Nations ou une autorité locale inuite | • សំបុត្រនៃការបញ្ជាក់នូវលំនៅដ្ឋាន មកពីកុលសម្ព័ន្ធជនជាតិដំបូង ឬទីបំរុងទុក ឬអាជ្ញាធរអ៊ីនូតមូលដ្ឋាន |

| | |
|---|---|
| • lettre de confirmation de résidence, attestation de séjour, formulaire d’admission ou relevé de prestations délivré par l’autorité responsable :<br>– d’une résidence pour étudiants<br>– d’une résidence pour personnes âgées<br>– d’un établissement de soins de longue durée<br>– d’un refuge<br>– d’une soupe populaire<br>– d’un établissement résidentiel communautaire | • សំបុត្រនៃការបញ្ជាក់នូវលំនៅដ្ឋាន, សំបុត្រនៃការស្នាក់, ទំរង់ការអនុញ្ញាតចូល, ឬរបាយការណ៍នៃអត្ថប្រយោជន៍ មកពីស្ថាប័នណាមួយ ដែលបានចាត់តាំងនៅខាងក្រោម៖<br>– លំនៅដ្ឋាននិស្សិត<br>– លំនៅដ្ឋានព្រឹទ្ធាវ័យ<br>– ស្ថាប័នថែទាំយូរអង្វែង<br>– ជម្រក<br>– កន្លែងផ្ដល់អាហារ<br>– មន្ទីរលំនៅដ្ឋានតាមសហគមន៍ |

មុខនៃ ID បន្ថែម អាចនឹងបានថែម។  យើងទទួលយករបាយការណ៍អេឡិកត្រូនិក និងវិក្កយប័ត្រអេឡិកត្រូនិក។  ផ្ញើតវា ឬបង្ហាញវា នៅលើឧបករណ៍ចល័ត។

## ជំរើសទី 3



+



### បើសិនអ្នកពុំមាន ID ទេ

អ្នកនៅតែអាចបោះឆ្នោតបាន បើសិនអ្នកប្រកាសអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក ជាលាយល័ក្ខណ៍អក្សរ និងឲ្យជនណាម្នាក់ដែលស្គាល់អ្នក និងដែលបានចាត់តាំង ទៅកន្លែងបោះឆ្នោតរបស់អ្នក ធានាថាស្គាល់អ្នក។

អ្នកធានា ត្រូវតែអាចបង្ហាញអត្តសញ្ញាណ និងអាសយដ្ឋានរបស់គេ។  មនុស្សអាចធានាបាន សំរាប់មនុស្សតែម្នាក់ប៉ុណ្ណោះ (លើកលែងតែស្ថាប័នថែទាំយូរអង្វែង)។

បញ្ជីសព្វគ្រប់នៃ ID ដែលអាចទទួលយកបាន គឺមានជាភាសាជាច្រើន នៅឯ **elections.ca**។

សំរាប់ទំរង់ផ្សេងទៀត ដូចជាអក្សរប្រៃល និងសំឡេង ហៅលេខ **1-800-463-6868**។